ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ :០១.កយក.សណន/២៤

# សេចក្តីណែនាំ

## នៅក្នុងមហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ទូទាំងប្រទេសឆ្នាំ ២០២៣ និងកំណត់ទិសដៅការងារជាអាទិភាពបន្ត

បន្ថែមលើទិសដៅការងារជាអាទិភាពបន្ត និងសេចក្តីសម្រេចចិត្តរួមរបស់មហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារជាអាទិភាពបន្ត ដែលបានប្រព្រឹត្តទៅរយៈពេល ៣ថ្ងៃពេញ ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ កន្លងទៅ និងដើម្បីធានាបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការបន្តអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ សំដៅសម្រេចឱ្យបានជោគជ័យនូវគោលដៅជាយុទ្ធសាស្ត្រក្នុង "ការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌" ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា និងវិធានការគន្លឹះទី៥ របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, ក្រសួងយុត្តិធម៌ សូមធ្វើការណែនាំបន្ថែម ដូចខាងក្រោម៖

ទី១-ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា និងតួអង្គដែលមានការពាក់ព័ន្ធទាំងអស់ ត្រូវបន្តចូលរួមដោយស្មោះត្រង់ និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្តយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ព្រមទាំងវិធានការម៉ឺងម៉ាត់ចំពោះសំណុំរឿងអាទិភាពទាំងបី គឺ សំណុំរឿងគ្រឿងញៀន, សំណុំរឿងគ្រោះថ្នាក់ចរាចរណ៍ និងសំណុំរឿងអគ្រានុកូលដ្ឋាន ឱ្យទទួលបានលទ្ធផលខ្ពស់។

ទី២-សម្រាប់ឆ្នាំ ២០២៤ នេះ, ការងារពង្រឹងវិន័យការងារ និងក្រមសីលធម៌ នៅតែបន្តជាការងារអាទិភាពរបស់ក្រសួងយុត្តិធម៌ និងរបស់សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និងធានាបានប្រសិទ្ធភាពនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌។ ហេតុដូចនេះ, ទាំងអង្គភាពជំនាញ ទាំងយន្តការវិន័យរបស់ក្រសួងយុត្តិធម៌ ទាំងយន្តការក្រុមប្រឹក្សាវិន័យរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវអនុវត្តវិធានការវិន័យឱ្យបានតឹងរ៉ឹង ម៉ឺងម៉ាត់ និងដោយគ្មានការយោគយល់ចំពោះអ្នកល្មើសវិន័យ ជាពិសេស ការជំរុញការអនុវត្តទណ្ឌកម្មវិន័យថ្នាក់ទី២ (ការផ្លាស់ប្តូរដោយបង្ខំ, ការព្យួរពីការងារ, ការបន្ថយថ្នាក់ ឬឋានន្តរស័ក្តិ, ការដាក់ឱ្យចូលនិវត្តន៍ដោយបង្ខំ, ការបញ្ឈប់ពីមុខងារដោយបង្ខំ និងការបណ្តេញចេញពីក្របខ័ណ្ឌ) ស្របតាមច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា និងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។ ពាក់ព័ន្ធនឹងការងារនេះ, នឹងមានការផ្សព្វផ្សាយជាសាធារណៈឱ្យបានទៀងទាត់អំពីវិធានការវិន័យម៉ឺងម៉ាត់ដែលត្រូវបានសម្រេចដោយក្រុមប្រឹក្សាវិន័យរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយគ្រាន់តែមិនបញ្ជាក់ឈ្មោះចៅក្រម ឬព្រះរាជអាជ្ញាដែលរងវិន័យ ប៉ុន្តែ ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីចំនួនសំណុំរឿងវិន័យដែលក្រុមប្រឹក្សាវិន័យបានចាត់ការ, ចំនួនចៅក្រម-ព្រះរាជអាជ្ញាដែលទទួលរងវិន័យ និងប្រភេទទណ្ឌកម្មវិន័យដែលត្រូវបានសម្រេច។

ទន្ទឹមនឹងការពង្រឹងវិន័យការងារ និងក្រមសីលធម៌នេះ, ក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នឹងបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់ការលើកទឹកចិត្តនានាដល់មន្ត្រីរាជការ និងមន្ត្រីតុលាការទាំងអស់



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

ដែលបានខិតខំប្រឹងប្រែងអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ប្រកបដោយស្មារតីបុរេសកម្ម, ភាពជាម្ចាស់, ការទទួលខុសត្រូវខ្ពស់, មានសាមគ្គីភាពផ្ទៃក្នុង និងកិច្ចសហប្រតិបត្តិការល្អ តាមរយៈការលើកកម្ពស់ការអនុវត្តនូវគោលការណ៍គុណាធិបតេយ្យ (Meritocracy) ក្នុងការរៀបចំតែងតាំង និងផ្លាស់ប្តូរមុខតំណែងទទួលខុសត្រូវនានានៅក្នុងវិស័យយុត្តិធម៌។

ទី៣-យន្តការទទួលបន្ទុកកិច្ចការព័ត៌មាន និងសាធារណមតិ នៃក្រសួងយុត្តិធម៌ និងសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅទូទាំងប្រទេស ត្រូវយកចិត្តទុកដាក់ខ្ពស់លើកិច្ចការព័ត៌មាន និងសាធារណមតិ ដោយត្រូវផ្លាស់ប្តូរពីការនាំពាក្យដែលមានលក្ខណៈជាប្រតិកម្មឆ្លើយតបនៅពេលមានការចោទប្រកាន់ (Reactive) ទៅជាការនាំពាក្យដែលមានលក្ខណៈបុរេសកម្ម (Proactive) ផង និងលក្ខណៈជាប្រតិកម្មឆ្លើយតប (Reactive) ផង ដោយសារការងារនាំពាក្យ និងសារព័ត៌មាន គឺជាកិច្ចការដ៏មានសារៈសំខាន់ និងចាំបាច់ក្នុងយុគសម័យឌីជីថល ដើម្បីផ្សព្វផ្សាយជូនសាធារណជន និងប្រជាពលរដ្ឋ ឱ្យបានដឹងនូវព័ត៌មានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ដើម្បីជាមូលដ្ឋានក្នុងការពិចារណា និងវាយតម្លៃប្រកបដោយសុទិដ្ឋិនិយមអំពីកិច្ចខិតខំប្រឹងប្រែងរបស់វិស័យយុត្តិធម៌ ជាពិសេស ក្នុងអំឡុងពេលនៃការអនុវត្តយុទ្ធនាការទាំង ២ ខាងលើ ដែលជាបេក្ខជីមួយសម្រាប់វិស័យយុត្តិធម៌របស់យើង។

ទី៤-សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងយកចិត្តទុកដាក់បន្ថែមទៀតក្នុងការដោះស្រាយឱ្យបានម៉ឺងម៉ាត់នូវសំណុំរឿងនានាដោយប្រកាន់យកភាពត្រឹមត្រូវ និងយុត្តិធម៌ជាគោលក្នុងចំណាត់ការ ហើយបន្ថែមការយកចិត្តទុកដាក់ជាអាទិភាពលើសំណុំរឿងដែលកើតមានញឹកញាប់ និងប៉ះពាល់ធ្ងន់ធ្ងរដល់សង្គម ជាពិសេស ករណីពាក់ព័ន្ធនឹងគ្រឿងញៀន, ក្មេងទំនើង, ឆក់, ប្លន់ ជាដើម ដើម្បីរួមចំណែកក្នុងការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ និងស្ថិរភាពសង្គម។ ទន្ទឹមនេះ, ចំពោះបទល្មើសទាំងនេះ សាលាជម្រះក្តីនីមួយៗត្រូវយកចិត្តទុកដាក់លើការអនុវត្តវិធានការបណ្តេញចេញពីកម្ពុជាចំពោះទណ្ឌិតជាជនបរទេស ក្រោយបញ្ចប់ការអនុវត្តទោសជាប់ពន្ធនាគារ។

ទន្ទឹមនេះ, ចៅក្រមទទួលបន្ទុកសំណុំរឿងរដ្ឋប្បវេណីនៅទូទាំងប្រទេស ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តតួនាទីរបស់ខ្លួន ប្រកបដោយភាពសកម្មក្នុងការត្រួតពិនិត្យភស្តុតាងនានាក្នុងសំណុំរឿងរដ្ឋប្បវេណី ដើម្បីស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ និងដើម្បីជាឧត្តមប្រយោជន៍នៃយុត្តិធម៌នៅក្នុងសង្គមជាតិ។

ទី៥-អង្គភាពជំនាញរបស់ក្រសួងយុត្តិធម៌ និងសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវពង្រឹងអភិបាលកិច្ចផ្ទៃក្នុងអង្គភាព ស្ថាប័នរបស់ខ្លួនឱ្យបានល្អប្រសើរ, មានសាមគ្គីភាពផ្ទៃក្នុងល្អ និងកិច្ចសហប្រតិបត្តិការល្អ។ ទន្ទឹមនេះ, ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងយុត្តិធម៌ ព្រមទាំងចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី អាជ្ញាសាលា និងមន្ត្រីតុលាការគ្រប់លំដាប់ថ្នាក់ទាំងអស់ ត្រូវពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ប្រកបដោយស្មារតីបុរេសកម្ម, ភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់។

ទី៦-ចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ ត្រូវខិតខំពង្រឹងគុណភាពនៃការសរសេរសាលក្រម, សាលដីកា ឬដីកានានា ឱ្យបានត្រឹមត្រូវតាមក្បួនខ្នាត, ងាយយល់, មានសំអាងហេតុ និងសំអាងច្បាប់ច្បាស់លាស់ និងគ្រប់គ្រាន់ ជាពិសេស ការលើកកម្ពស់គុណភាពនៃការសម្រេចសេចក្តីឱ្យបានត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមច្បាប់ និងនីតិវិធីជាធរមាន ដើម្បីមានមូលដ្ឋានរឹងមាំក្នុងការអនុវត្តនៅពេលដែលសេចក្តីសម្រេចទាំងនេះ ចូលជាស្ថាពរ។ ទន្ទឹមនេះ, ចៅក្រម និងព្រះរាជអាជ្ញាទាំងអស់ ត្រូវមានការទទួលខុសត្រូវចំពោះកិច្ចការដែលខ្លួនទទួលបន្ទុក ជាពិសេស ចៅក្រម និងព្រះរាជអាជ្ញា ដែលនឹងត្រូវផ្លាស់ប្តូរកន្លែងបំពេញការងារ ត្រូវរៀបចំចេញសាលក្រម ឬសាលដីកា ឬដីកាសម្រេច ចំពោះសំណុំរឿងដែលខ្លួនបានប្រកាសរួចហើយ ឱ្យបានរួចរាល់មុននឹងផ្លាស់ទៅកន្លែងថ្មី។ 6

ទី៧-ដោយការពង្រឹងសមត្ថភាពមន្ត្រីក្នុងវិស័យយុត្តិធម៌នៅតែជាអាទិភាពការងារដ៏សំខាន់ ដើម្បីគាំទ្រដល់ការពង្រឹងប្រសិទ្ធភាពនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌, បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ជាពិសេសសាលាច្បាប់, អគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌, សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវសហការគ្នាធ្វើការសិក្សា និងវាយតម្លៃអំពីតម្រូវការ ដើម្បីដាក់ចេញនូវផែនការអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្សក្នុងវិស័យយុត្តិធម៌ ទាំងសម្រាប់មន្ត្រីបម្រើការនៅក្រសួងយុត្តិធម៌ ទាំងមន្ត្រីរដ្ឋបាលតុលាការ ទាំងចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីតុលាការទាំងអស់ ឱ្យបានឆាប់ និងអាចឆ្លើយតបបានទៅនឹងការវិវត្តយ៉ាងឆាប់រហ័សក្នុងសង្គម ជាពិសេស ការយកចិត្តទុកដាក់ខ្ពស់លើការងារបរិវត្តកម្មឌីជីថល និងបច្ចេកវិទ្យា សំដៅធ្វើយ៉ាងណាទាញយកឱ្យអស់សក្តានុពលពីបច្ចេកវិទ្យាថ្មីនេះ សម្រាប់បម្រើដល់ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពការងារក្នុងវិស័យយុត្តិធម៌ ព្រមទាំងការអភិវឌ្ឍខ្លួនឱ្យទាន់ដំណើរវិវត្តឈានឡើងជាលំដាប់ដ៏ឆាប់រហ័សនៃវិស័យបច្ចេកវិទ្យាក្នុងសង្គមសម័យទំនើបបច្ចុប្បន្ន។

ទន្ទឹមនេះ, អង្គភាពជំនាញក្រោមឱវាទក្រសួងយុត្តិធម៌ និងសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ក៏ត្រូវបន្តយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងសមត្ថភាពធនធានមនុស្សរបស់ខ្លួនផងដែរ តាមរយៈការពង្រឹងលើការសិក្សាស្រាវជ្រាវ ការរៀបចំជាសិក្ខាសាលា វគ្គបណ្តុះបណ្តាល ឬកម្មវិធីចែករំលែកនូវចំណេះដឹង និងបទពិសោធន៍ថ្មីៗដល់មន្ត្រីរាជការដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ហើយក្រសួងយុត្តិធម៌នឹងផ្តល់ជាការគាំទ្រជាបច្ចេកទេសតាមតម្រូវការចាំបាច់ ។ ម្យ៉ាងទៀត, មន្ត្រីគ្រប់រូបក្នុងវិស័យយុត្តិធម៌ក៏ត្រូវយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពរបស់ខ្លួនជាប់ជាប្រចាំផងដែរ ដើម្បីអាចសម្របខ្លួនបានទាន់នឹងការវិវត្តយ៉ាងឆាប់រហ័ស ក្នុងសង្គម និងវិស័យយុត្តិធម៌ ។

ទទួលបានសេចក្តីណែនាំនេះ សូម **ឯកឧត្តម លោកជំទាវ** ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងយុត្តិធម៌ និងសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ព្រមទាំងតួអង្គដែលមានការពាក់ព័ន្ធ ត្រូវចាត់ចែងអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**ចម្លងជូន៖**

- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
- សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
- ឯកសារ កាលប្បវត្តិ